**AUSTRALIAN EMBASSY**
**PHNOM PENH**

# សេចក្តីប្រកាសព័ត៌មាន

## <u>អូស្ត្រាលីជួយដល់អ្នកដែលលេចធ្លោនៅកម្ពុជា</u>

និស្សិតកម្ពុជាចំនួន១៨នាក់ ដែលបានទទួលអាហារូបករណ៍អូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍(ADS) នឹងត្រូវទទួលបានការស្វាគមន៍ក្រោយការត្រឡប់មកវិញ នៅឯពិធីមួយដែលរៀបចំដោយលោកជំទាវឯកអគ្គរាជទូតអូស្ត្រាលីនៅថ្ងៃទី ១ ខែតុលា ឆ្នាំ២០០៩។ ក្រោយពីបានបំពេញការសិក្សាអស់រយៈពេល១ ទៅ ២ឆ្នាំ នៅប្រទេសអូស្ត្រាលីមក និស្សិតអាហារូបករណ៍ទាំងនេះបានទទួលជោគជ័យក្នុងការសិក្សា នៅតាមសកលវិទ្យាល័យអូស្ត្រាលី និងទទួលបាននូវសញ្ញាបត្រ័ថ្នាក់អនុបណ្ឌិតក្នុងមុខជំនាញ ច្បាប់ រដ្ឋបាលសាធារណៈ គណនេយ្យ ការសិក្សាអំពីការអភិវឌ្ឍន៍ ការអប់រំ សុខភាពសាធារណៈ និងវិទ្យាសាស្ត្រកសិកម្ម។

លោកជំទាវឯកអគ្គរាជទូត ម៉ាហ្គារ៉េត អាដាមសុន (Margaret Adamson) បានមានប្រសាសន៍ថា “ក្រុមជនវ័យក្មេងដែលប្រកបដោយទេពកោសល្យ និងភាពរស់រវើកទាំងនេះ តំណាងអោយការវិនិយោគដ៏ធំធេងនៅក្នុងធនធានមនុស្ស។ ជំនាញ និងបទពិសោធន៍ដែលពួកគេបាននាំនាំមក នឹងក្លាយជាទ្រព្យសម្បត្តិដ៏មានតំលៃសំរាប់វិស័យឯកជន និងសាធារណៈរបស់ប្រទេសកម្ពុជា ” ។

លោកជំទាវបានបន្ថែមទៀតថា “ប្រទេសអូស្ត្រាលីបានផ្តល់អាហារូបករណ៍ដល់កម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយ គឺគិតចាប់តាំងពីជំនាន់ផែនការកូឡុមបូនៅក្នុងទសវត្សឆ្នាំ១៩៥០។ នេះបង្ហាញអំពីគុណតំលៃដែលយើងផ្តល់អោយនៅក្នុងការកសាងទំនាក់ទំនងដ៏យូរអង្វែងជាមួយប្រទេសជិតខាងនៅក្នុងតំបន់របស់យើង” ។

ជារៀងរាល់ឆ្នាំ មានអាហារូបករណ៏រហូតដល់ចំនួន១.០០០នាក់ ត្រូវបានផ្តល់ដល់ប្រទេសចំនួន៣១ ដើម្បីដោះស្រាយនូវបញ្ហាអាទិភាព គឺតំរូវការអភិវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេសជាដៃគូររបស់យើង។ ចាប់ពីឆ្នាំ២០០៦ ចំនួនអាហារូបករណ៏ដែលផ្តល់អោយតំបន់អាស៊ីប៉ាស៊ីភិចបានកើនឡើងទ្វេរដង រហូតដល់ចំនួន ១៩.០០០ដែលរួមមានទឹកប្រាក់ចំនួន ១,៤ពាន់លានដុល្លាអូស្ត្រាលីក្នុងរយៈពេលប្រាំឆ្នាំ។

នៅកម្ពុជា អូស្ត្រាលីផ្តល់អាហារូបករណ៏ថ្នាក់អនុបណ្ឌិតរហូតដល់ចំនួន ២៥ នាក់ក្នុងមួយឆ្នាំៗ។ លើសពីនេះ ចំពោះនិស្សិតកម្ពុជាដែលមានសក្តានុពលក្នុងការដឹកនាំ អាចទទួលបាននូវអាហារូបករណ៏អូស្ត្រាលីសំរាប់ភាពជាអ្នកដឹកនាំ (ALA) ក្រោមការប្រកួតប្រជែងថ្នាក់តំបន់ សំរាប់បន្តការសិក្សាថ្នាក់បណ្ឌិតនិងអនុបណ្ឌិត និងបង្កើតបណ្តាញទំនាក់ទំនងនៅថ្នាក់ជាតិ តំបន់ និងទូទាំងពិភពលោក។ ចាប់ពីឆ្នាំ២០០៧ មកអាហារូបករណ៏នេះបានផ្តល់ដល់និស្សិតកម្ពុជាចំនួន១៩នាក់រួចមកហើយ។ ក្រៅពីនេះ មានកម្មវិធីបណ្តុះបណ្តាលវគ្គខ្លីៗសំរាប់អភិវឌ្ឍសមត្ថភាព

16B National Assembly Street, Sangkat Tonle Bassac Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

និងជំនាញ (ALF) ដែលអាចផ្តល់អោយកម្ពុជារហូតដល់ចំនួន៤០នាក់ក្នុងមួយឆ្នាំៗ សំរាប់បន្តការសិក្សាវគ្គជំនាញវិជ្ជាជីវៈនៅប្រទេសអូស្ត្រាលី ។

ចាប់តាំងពីកម្មវិធីអាហារូបករណ៍អូស្ត្រាលីសំរាប់ការអភិវឌ្ឍន៏ (ADS) ត្រូវបានបង្កើតនៅឆ្នាំ១៩៩៤មក មាននិស្សិតកម្ពុជាចំនួន៣០០នាក់រួចមកហើយ ដែលបានទទួលអាហារូបករណ៏សំរាប់ការសិក្សាកំរិតឧត្តមសិក្សានៅសកលវិទ្យាល័យនិងវិទ្យាស្ថានបច្ចេកទេសនានារបស់អូស្ត្រាលី ។ ពួកគេបានត្រឡប់មកវិញ ដោយចូលរួមក្នុងការអភិវឌ្ឍន៏សេដ្ឋកិច្ចនិងសង្គមរបស់កម្ពុជា ហើយក្នុងចំណោមនោះ មានមួយចំនួនធំបានកាន់តួនាទីខ្ពស់ៗនៅក្នុងជួររដ្ឋាភិបាលនិងវិស័យឯកជន ។

សំរាប់ព័ត៌មានបន្ថែមអំពីអាហារូបករណ៏អូស្ត្រាលី សូមពិនិត្យៈ
www.ausaid.gov.au/scholar/default.cfm or www.australianscholarships.gov.au

**ទំនាក់ទំនងការផ្សាយៈ លោកស្រី ហ្វីយ៉ូណា ខស្សូ លេខាទី១**

**ទូរស័ព្ទលេខៈ ០២៣ ២១៣ ៤៧០ ស្ថានទូតអូស្ត្រាលីនៅភ្នំពេញ**

**ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩**